ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

---

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier Nº. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Phillip RAPOZA**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២៣
**ភាសាដើម៖** ខ្មែរ/អង់គ្លេស
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 28-Apr-2023, 14:58
CMS/CFO: Sann Rada

---

# ដីកាបង្គាប់អង្គភាពបណ្ណសារស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុង សំណុំរឿង ០០២

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Fergal GAYNOR (បម្រុង)

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Falguni DEBNATH

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

## I. សេចក្តីផ្តើម

1. ដោយយោងទៅលើ"សេចក្តីសម្រេចស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារសំណុំរឿង ០០២" ("សេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ") របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៣ ដែលបានអនុម័តសេចក្តីណែនាំទូទៅសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ("សំណុំរឿង ០០២")។

2. ដោយអនុលោមតាមមាត្រា ១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ និងការគ្រប់គ្រងព័ត៌មានដែលពាក់ព័ន្ធ (វិសោធនកម្មលើកទីមួយ) ("សេចក្តីណែនាំអនុវត្តស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារ") អង្គជំនុំជម្រះតុលាការកំពូលដែលជាតុលាការចុងក្រោយក្នុងការទទួលសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ("សំណុំរឿង ០០២") បានចាប់ផ្តើមធ្វើការពិនិត្យឡើងវិញលើឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងនេះសម្រាប់គោលបំណងធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញស្របតាមសេចក្តីសម្រេចស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។

## II. ការបង្គាប់ទៅអង្គភាពបណ្ណសារ

3. អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់អង្គភាពបណ្ណសារ ("RAU") ត្រូវដកចំណាត់ថ្នាក់ឯកសារសំណុំរឿង ០០២ ដូចមានក្នុងតារាងបញ្ជីឯកសារភ្ជាប់ជាមួយ ("ឧបសម្ព័ន្ធ ក")។ ដើម្បីសម្រួលដល់ការកោសលុបឯកសារ D3, D108/55, D83, និង D196 ឧបសម្ព័ន្ធបួនបន្ថែមទៀត (ឧបសម្ព័ន្ធ ក(i), ក(ii), ក(iii) និង ក(iv)) ត្រូវបានភ្ជាប់ជាមួយ។ ការធ្វើចំណាត់ថ្នាក់ឯកសារទាំងនេះត្រូវបានបញ្ជាក់ដូចខាងក្រោម៖

ក. "ដកចំណាត់ថ្នាក់" មានន័យថា ឯកសារគប្បីដាក់ចំណាត់ថ្នាក់ទៅជាសាធារណៈ

ខ. "ពុំត្រូវការចំណាត់ការ" មានន័យថា ពុំចាំបាច់ធ្វើចំណាត់ការ និង

គ. "ធ្វើការកោសលុប" មានន័យថា ឯកសារគប្បីត្រូវកោសលុបនូវព័ត៌មានដែលរសើប ឬបញ្ជាក់ពីអត្តសញ្ញាណ (ជាទូទៅដូចជា ឈ្មោះ ព័ត៌មានទំនាក់ទំនងលម្អិត ដូចជាលេខទូរ

សំព្ទ ឬអាសយដ្ឋានទីលំនៅ) ស្របតាមសេចក្តីណែនាំដែលមានក្នុងសេចក្តីសម្រេចស្តីពីការធ្វើ ចំណាត់ថ្នាក់ឯកសារ។

ជាគោលការណ៍ទូទៅ អង្គជំនុំជម្រះតុលាការកំពូលតម្រូវថា រាល់ឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ និងសាក្សីដែលត្រូវបានការពាររួមទាំងព័ត៌មានបញ្ជាក់អំពីអត្តសញ្ញាណ ដូចជាសេចក្តីលម្អិតនៃការទំនាក់ទំនង និងព័ត៌មានពាក់ព័ន្ធនឹងគ្រួសារដែលមានក្នុងឯកសារណាមួយនោះ ត្រូវកោសលុប។

## IV. ផ្នែកសម្រេចសេចក្ដី

យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះសម្រេច÷**

**បង្គាប់ឱ្យអង្គភាពបណ្ណសារ**ដកចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿង ០០២ ស្របតាមបញ្ជីឯកសារភ្ជាប់ជាមួយ (“ឧបសម្ព័ន្ធ ក”) និងតាមសេចក្ដីសម្រេចស្ដីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។ បន្ទាប់ពីបានជូនដំណឹងដល់ភាគីទាំងអស់ អង្គភាពបណ្ណសារតម្រូវឱ្យផ្សព្វផ្សាយបញ្ជីឯកសារទាំងអស់ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាសាធារណៈក្រោយពីការដកចំណាត់ថ្នាក់នេះរួច។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**